ព្រឹត្តិបត្រព័ត៌មាន ស្តីពីការបង្ការជំងឺឆ្លងរបស់សិស្ស ក្បាំងសាំងណាមដូ



លេខ26-01(ត្រីមាសទី1 ឆ្នាំ2026)

ត្រៀមសុខភាពសម្រាប់ឆមាសថ្មី ជាមួយនឹងការចាក់វ៉ាក់សាំង!

ព័ត៌មានអំពីការចាក់វ៉ាក់សាំងជាតម្រូវការសម្រាប់សិស្សថ្មី

វ៉ាក់សាំងដែលបានចាក់នៅជាទារកអាចធ្វើឱ្យប្រព័ន្ធភាពស៊ាំចុះ ខ្សោយ ទៅតាមពេលវេលាដែលកន្លងទៅ។ ដើម្បីជានាបាន នូវសុខភាពរបស់កុមារដែលចាប់ផ្តើមរស់នៅជាក្រុម សូមចាក់វ៉ាក់សាំងចាំបាច់ឱ្យបានពេញលេញ។



DTaP(ឆាតខាន់ស្លាក់, តេតាណូស, ក្អកមាន់) 5ដូស, IPV(ជំងឺស្ទឹតដៃជើង) 4ដូស, MMR (កញ្ជ្រឹល, ស្រឡះទន, ស្ទូច) 2ដូស, រលាកខួរក្បាលជប៉ុន 4ដូស (វ៉ាក់សាំងអសកម្ម) ឬ 2ដូស(វ៉ាក់សាំងរស់)



Tdap (ជំងឺខាន់ស្លាក់, តេតាណូស, ក្អកមាន់) ដូសទី6(ឬ Td) ជំងឺរលាកខួរក្បាលជប៉ុន ដូសទី5 (អសកម្ម) ឬដូសទី2 (វ៉ាក់សាំងរស់) HPV (មេរោគ papillomavirus របស់មនុស្ស) ដូសទី1

*គេហទំព័រជំនួយការចាក់វ៉ាក់សាំង (https://nip.kdca.go.kr) ▶ ពិនិត្យមើលប្រវត្តិចាក់វ៉ាក់សាំង

ខ្ញុំចង់ដឹង! Q&A អំពីការចាក់វ៉ាក់សាំង ការពារជំងឺផ្តាសាយ (គ្រុនផ្តាសាយ)

Q ខ្ញុំបានចាក់កាលពីឆ្នាំមុន(ខែ10 ឆ្នាំ2025), តើខ្ញុំត្រូវការចាក់វ៉ាក់សាំងម្តងទៀតនៅឆ្នាំនេះ(ខែ03 ឆ្នាំ2026) ដែរឬទេ?

A អត់ទេ។ ការចាក់វ៉ាក់សាំងការពារជំងឺផ្តាសាយ ត្រូវបានផ្តល់ឱ្យ តាមរដូវកាល(ខែ09~ខែ04នៃឆ្នាំបន្ទាប់)។ បើអ្នកបានចាក់ កាលពី រដូវស្លឹករលើផ្ទៃមុន វានឹងនៅតែមាន ប្រសិទ្ធភាព រហូតដល់រដូវផ្តាសាយនេះ ដូច្នេះអ្នកមិនចាំបាច់ចាក់វ៉ាម្តងទៀតទេ។ (កាលបរិច្ឆេទចាក់វ៉ាក់សាំងបន្ទាប់ ដែលបានណែនាំ៖ រដូវស្លឹក ឈើជ្រុះ ឆ្នាំ2026)

Q ខ្ញុំបានឮថាខ្ញុំនៅតែអាចកើតជំងឺផ្តាសាយបាន ទោះបីជាបានចាក់វ៉ាក់សាំងការពារជំងឺផ្តាសាយរួចហើយក៏ដោយ។ ហេតុអ្វីគួរតែចាក់វ៉ា

A ទោះបីជាអ្នកឆ្លងជំងឺផ្តាសាយក៏ដោយ ឆាតសញ្ញានឹង ស្រាល ជាងច្រើន ហើយអ្នកអាចការពារផលវិបាក ដូចជាជំងឺរលាកសួត ឬការវិវត្តទៅជាជំងឺធ្ងន់ធ្ងរ។



មុន·ក្រោយពេលចាក់វ៉ាក់សាំង ត្រូវចងចាំរឿងនេះអោយច្បាស់!

មុនពេលចាក់វ៉ាក់សាំង



ទៅជួបគ្រូពេទ្យនៅថ្ងៃដែលអ្នកមានសុខភាពល្អ



អនីតិជនត្រូវតែមានអាណាព្យាបាលទៅជាមួយ ក្មេងដែលមិនមានអាណាព្យាបាលទៅជាមួយបាន
① យកទម្រង់បែបបទយល់ព្រមពីអាណាព្យាបាល* និង
② ទម្រង់បែបបទពិនិត្យបឋម** ដែលបានបំពេញជាមុន។

*អ្នកអាចទាញយកទម្រង់បែបបទយល់ព្រមនិងកាលវិភាគ ចាក់វ៉ាក់ សាំង ពីគេហទំព័រជំនួយការចាក់វ៉ាក់សាំង ▶ ការគ្រប់គ្រងការ ចាក់វ៉ាក់សាំង ▶ ដោនឡូតយកក្រដាសពាក់ព័ន្ធ
**បំពេញទម្រង់បែបបទចាក់វ៉ាក់សាំងអមឡិចត្រូនិចនៅលើ គេហទំព័រជំនួយការចាក់វ៉ាក់សាំង

ក្រោយពេលចាក់វ៉ាក់សាំង



បន្ទាប់ពីចាក់វ៉ាក់សាំងរួច សូមស្នាក់នៅ ស្តាប់ន ផ្ទៃសាស្ត្រ រយៈពេល20~30នាទី ដើម្បីសង្កេត មើល ប្រតិកម្មមិនល្អ



ពិនិត្យមើលកាលវិភាគចាក់វ៉ាក់សាំងបន្ទាប់របស់អ្នក (ចុះឈ្មោះសម្រាប់សេវាកម្មជូនដំណឹងជាមុន)



ក្នុងករណីមានប្រតិកម្មមិនល្អដូចជាគ្រុនក្តៅខ្លាំង ឬឈឺចាប់ខ្លាំង

1. សូមពិគ្រោះជាមួយស្តាប៊ន ផ្ទៃសាស្ត
2. រាយការណ៍ទៅកាន់មណ្ឌលសុខភាពសាធារណៈរបស់អ្នក ឬចូលទៅកាន់គេហទំព័រជំនួយការចាក់វ៉ាក់សាំង រាយការណ៍អាចត្រូវបានធ្វើឡើងនៅក្រោម “ប្រតិកម្មមិនល្អបន្ទាប់ពីការចាក់វ៉ាក់សាំង”




경상남도 GYEONGNAM · 경상남도 감염병관리지원단 Gyeongnam Center for Infectious Disease Control and Prevention · 경상남도교육청 GYEONGSANGNAMDO OFFICE OF EDUCATION · 경상남도가족센터 GYEONGSANGNAMDO FAMILY CENTER

ត្រូវប្រាកដថាពិនិត្យមើលរោគសញ្ញា និងលក្ខខណ្ឌចូលរៀនៗ

ជំងឺអុតស្វាយ, តើវាជាអ្វី?

ជំងឺវីរុសដែលឆ្លងខ្លាំងៗ



ផ្លូវឆ្លងមេរោគ



នៅពេលប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺដែលមានជំងឺអុតស្វាយ



ពេលអ្នកជំងឺអុតស្វាយក្អក ឬកណ្តាស់

រយៈពេលភ្ញាស់

ជាធម្មតា10~21ថ្ងៃ
(ជាមធ្យម 14~16ថ្ងៃ)



រោគសញ្ញាសំខាន់ៗ និងការវិវត្តន៍



គ្រុនក្តៅទាប, អស់កម្លាំង

កន្ទួលចាប់ផ្តើមនៅលើមុខ ឬដើមទ្រូង

រាលដាលដល់អវយវៈ

ចំណុចក្រហមតូចមួយ (ប៉ោងបន្តិច)

ផ្លោក(ពងបែក)

អាប់ស(ពងបែកដែលពោរពេញទៅដោយខ្ទុះ)

ការជាសះស្បើយឡើងវិញជាមួយនឹងស្នាមប្រេះ



តើវាឆ្លងរាលដាលរយៈពេលប៉ុន្មាន?

- 1~2ថ្ងៃមុនពេលកន្ទួលចាប់ផ្តើមឡើង
- រហូតដល់ពងបែកទាំងអស់មានសំបក



វិធីធ្វើចត្តាឡីស្រ្តីក ករណីមានជំងឺអុតស្វាយ(សេចក្តីជូនដំណឹង អំពីការផ្អាកការសិក្សា

- កុំទៅសាលារៀន·មណ្ឌលថែទាំកុមារ រហូតដល់ពងបែកទាំងអស់បានបកចេញ(យ៉ាងហោចណាស់5ថ្ងៃបន្ទាប់ពីកន្ទួលលេចឡើង)



- បើមានតែចំណុច ឬដុំពកលេចឡើងដោយគ្មានជំបៅ ការដាក់ឱ្យ នៅដាច់ដោយឡែក រហូតដល់គ្មានជំបៅស្បែកថ្មីលេចឡើងរយៈពេល24ម៉ោង



ការគ្រប់គ្រងគ្រួសារ

- ប្រើប្រាស់បន្ទប់ទឹកដាច់ដោយឡែក
- ពីគ្នានៅពេលដែលអាចធ្វើទៅបាន ប្រើប្រាស់ចាន·កន្សែងដាច់ដោយឡែកពីគ្នា



ពេលទៅមន្ទីរពេទ្យ


- សូមទូរស័ព្ទមកជាមុន
- ពាក់ម៉ាស់អំឡុងពេលព្យាបាល កាត់បន្តយការប៉ះពាល់ជាមួយអ្នកជំងឺដទៃទៀត



ការគ្រប់គ្រងអ្នកមានទំនាក់ទំនង

- ការចាក់វ៉ាក់សាំងត្រូវបានណែនាំក្នុងរយៈពេល72ម៉ោង
- បន្ទាប់ពីការប៉ះពាល់ការតាមដានរោគសញ្ញារយៈពេល21ថ្ងៃ

គន្លឹះក្នុងការបង្ការជំងឺអុតស្វាយដើម្បីការពារខ្លួននិងមិត្តភក្តិ



ពិនិត្យមើលស្ថានភាពចាក់វ៉ាក់សាំង និងចាក់វ៉ាក់សាំងពេញលេញសម្រាប់អ្នកដែលមិនទាន់ចាក់វ៉ាក់សាំង



លាងដៃជាមួយសាប៊ូក្រោមទឹកដែលកំពុងហូរលើសពី 30 វិនាទី



គ្របមាត់ និងច្រមុះរបស់អ្នកដោយក្រដាសជូតមាត់ ឬដៃអាវរបស់អ្នកនៅពេលក្អក ឬកណ្តាស់



សម្អាត និងសម្លាប់មេរោគលើវត្ថុដែលប៉ះពាល់ញឹកញាប់



តាមដានរោគសញ្ញាដែលសង្ស័យ ពេលមានគ្រុនក្តៅ ឬកន្ទួលរមាស់, សូមស្វែងរកការព្យាបាលពីគ្រូពេទ្យ ហើយកុំទៅសាលារៀន

경상남도 GYEONGNAM
경상남도 감염병관리지원단 Gyeongnam Center for Infectious Disease Control and Prevention
경상남도교육청 GYEONGSANGNAMDO OFFICE OF EDUCATION
경상남도가족센터 GYEONGSANGNAMDO FAMILY CENTER